មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

3

# របាយការណ៍សង្ខេប

## វគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តន៍យុទ្ធសាស្ត្រ បង្កើនការស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេង ដោយប្រើឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង ( យុទ្ធសាស្ត្រ Three I’s )




PHD, Prey Veng 12 - 13 July 2010

រៀបចំដោយ

ឧបត្ថម្ភដោយ

# របាយការណ៍សង្ខេប

## វគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តន៍យុទ្ធសាស្ត្រ បង្កើនការស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេង ដោយប្រើឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង

## ( យុទ្ធសាស្ត្រ Three I's )

**១. ទីកន្លែង : មន្ទីរសុខាភិបាលខេត្ត ព្រៃវែង**

**២. កាលបរិច្ឆេទ :** ១២ - ១៣ ខែ កក្កដា ឆ្នាំ ២០១០

**៣. គោលបំណងនៃវគ្គបណ្តុះបណ្តាល :**

១- ផ្តល់ពត៌មានស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើនការស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការដោយប្រើឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

២- បង្កើនចំណេះដឹង និងជំនាញចាំបាច់ទាក់ទងនិងការអនុវត្តន៍យុទ្ធសាស្ត្រ 3 I's ជូនដល់មន្ត្រីផ្តល់សេវាថែទាំ និងព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគដស៍ និងអ្នកជំងឺអេដស៍

៣- រៀបចំផែនការសំរាប់អនុវត្តន៍យុទ្ធសាស្ត្រ 3 I's នៅសេវាថែទាំ និងព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍នៃមន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យបង្អែកស្រុក។

**៤. សកម្មភាព :**

**សមាសភាពនៃគណៈអធិបតី :**

១- ឯកឧត្តម. **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

២- លោកវេជ្ជ. **ខៅ ហួរ** អនុប្រធានមន្ទីរសុខាភិបាលខេត្ត ព្រៃវែង

**សមាសភាពចូលរួម :**

- មកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ចំនួន ១៥ នាក់
- មកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺ របេង-ហង់សិន ចំនួន ៧ នាក់
- មកពីមន្ទីរសុខាភិបាលខេត្ត ព្រៃវែង ចំនួន ២៧ នាក់
- ស្រុកប្រតបត្តិ អ្នកលឿង ចំនួន ២១ នាក់
- មកពីអង្គការក្រៅរដ្ឋាភិបាល ចំនួន ៣ នាក់

**ថ្ងៃទី ១ : ១២ កក្កដា ២០១០**

**ពេលព្រឹកៈ**

- ការងាររដ្ឋបាល និងគណៈនេយ្យ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- មតិស្វាគមន៍របស់លោកវេជ្ជ. **ខៅ ឃួរ** អនុប្រធានមន្ទីរសុខាភិបាលខេត្ត ព្រៃវែង
    - ស្ថានភាពភូមិសាស្រ្ត ខេត្ត ព្រៃវែង
    - តំបន់អភិវឌ្ឍន៍ខេត្ត ព្រៃវែង
    - សេវាសុខាភិបាល និង ការបង្ការ និង ការថែទាំ និងព្យាបាលជំងឺអេដស៍ នៅក្នុងខេត្ត
    - ទិសដៅទៅថ្ងៃអនាគត

- មតិសំណេះសំណាលរបស់លោកវេជ្ជ. **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគបាន មានមតិកោតសរសើរ និងថ្លែងអំណរគុណ ដល់ការខិតខំប្រឹងប្រែង របស់ មន្រ្តី សុខាភិបាល ទាំងអស់ក្នុងការទប់ស្កាត់ ការរាតត្បាតរបស់អេដស៍ នៅក្នុងខេត្តស្វាយរៀង និងកំពង់ស្ពឺ ទាំងមូល កន្លងមក ពិសេសក្រុមគ្រូពេទ្យ **OI/ART** ដែលបានផ្តល់សេវាដល់អ្នកជំងឺបានល្អប្រសើរ។ និងផ្តោត លើកិច្ច សហប្រតិបត្តការណ៍ ល្អ របស់មជ្ឈមណ្ឌលជាតិទាំងពីរគឺ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេង និងហង់សិន ក្នុងការងាររបេង-អេដស៍ ។

- ការបង្ហាញខ្លួន និង បទបញ្ជាក្នុងកិច្ចប្រជុំ បណ្តាញអ្នកផ្តល់ប្រឹក្សាលើការព្យាបាលជំងឺអេដស៍
- ការបង្ហាញពីកម្មវិធី និងគោលនៃកិច្ចប្រជុំបណ្តាញអ្នកផ្តល់ប្រឹក្សាលើការព្យាបាលជំងឺអេដស៍
- ការបង្ហាញរបស់លោកវេជ្ជ. **ស៊ឹម សុផៃ** មន្រ្តីផ្នែកថែទាំជំងឺអេដស៍ NCHADS ស្តីពីបទ ឧទ្ទេសនាមអំពីខ្លឹមសារ នៃនិយាមនៃបែបបទសំរាប់អនុវត្តការបង្កើន ការស្រាវជ្រាវករណីជំងឺរបេង ការព្យាបាល បង្ការជំងឺរបេង ដោយប្រើឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង ( យុទ្ធសាស្រ្ត Three I's ) នៅតាមបណ្តាសេវាថែទាំព្យាបាលបន្ត សំរាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ :
    - ការបង្កើនការស្រាវជ្រាវ
    - ការពិនិត្យសុខភាពរករកសញ្ញាជំងឺរបេង ក្នុងរយៈពេល ៤សប្តាហ៍កន្លងមក
    - ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ចំពោះអ្នកបានពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងទទួលលទ្ធផលវិជ្ជមាន
- ការបង្ហាញរបស់លោកវេជ្ជ. **ខៅ ម៉ានិត** មន្រ្តី CENAT ស្តីពី ការព្យាបាលបង្ការជំងឺរបេងដោយប្រើឱសថ Isoniazid :
    - ការព្យាបាលជំងឺរបេងដោយប្រើឱសថបង្ការ Isoniazid សំរាប់អ្នកផ្ទុកមេរោគអេដស៍

- តេស្តទុយប៊ែគុលលីនលើស្បែក ( TST )
- ការពិនិត្យសុខភាពរករោគសញ្ញា ឬកត្តាប្រឈមមុខនឹងជំងឺរបេងលើកុមារ
- IPT សំរាប់កុមារ

- លោក. **កែវ វណ្ណៈ** មន្ត្រីផ្នែកថែទាំជំងឺអេដស៍ NCHADS ស្តីពី ការពិនិត្យសុខភាពរកសញ្ញាជំងឺរបេង

  ♦ប្រើប្រាស់សំនួររករោគសញ្ញាសង្ស័យនៃជំងឺរបេងនៅពេលធ្វើការពិនិត្យសុខភាពអ្នកជំងឺដែលផ្ទុកមេរោគអេដស៍

  ♦ប្រើប្រាស់ ឯកសារសំរាប់កត់ត្រា នៅពេលធ្វើការសុខភាពរករោគសញ្ញាជំងឺរបេងនៅ លើអ្នកផ្ទុកមេរោគអេដស៍

  ♦បង្ហាញពីចរន្តបញ្ជូនអ្នកជំងឺនៅពេលធ្វើការពិនិត្យសុខភាពរកជំងឺរបេងនៅលើអ្នកផ្ទុកមេរោគអេដស៍

  ♦ អនុវត្តន៍ការបំពេញទំរង់បែបបទក្នុងការបញ្ជូន

- លោកវេជ្ជ. **ស៊ឹម សុផៃ** មន្ត្រីផ្នែក AIDS Care និងលោកវេជ្ជ. **ឃុន គីមអ៊ាម** អនុប្រធានការិយាល័យបច្ចេកទេសមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង និង ហង់សិន ធ្វើការបង្ហាញ ស្តីពី ការពិនិត្យ និងពិភាក្សាអំពីការ ប្រើប្រាស់គំនូសបំព្រួញសំរាប់ការផ្តល់ការព្យាបាលបង្ការដោយប្រើឱសថ Isoniazide ( IPT) សំរាប់មនុស្ស ពេញវ័យ និង កុមារ :

  ♦ការពិនិត្យ និងការពិភាក្សាអំពីការប្រើប្រាស់ គំនូសបំព្រួញសំរាប់ផ្តល់ IPT

  ♦ ការសង្ខេបលើការប្រើប្រាស់គំនូសបំព្រួញ

**<u>ពេលល្ងាចៈ</u>**

- លោកវេជ្ជ. **ឃុន គីមអ៊ាម** អនុប្រធានបច្ចេកទេស CENAT ធ្វើការបង្ហាញស្តីពី ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ រកជំងឺរបេង :

  ♦ការវាយតំលៃដើម្បីធ្វើរោគវិនិច្ឆ័យជំងឺរបេងត្រូវធ្វើឡើងដោយគ្រូពេទ្យថែទាំជំងឺ របេង

  ♦អ្នកផ្ទុកមេរោគអេដស៍ណាមានជំងឺរបេងសកម្មត្រូវធ្វើការចុះបញ្ជីភ្លាមហើយត្រូវទទួល ការព្យាបាលសមស្រប

  ♦ អ្នកជំងឺដែលផ្ទុកមេរោគអេដស៍ហើយកើតជំងឺរបេង ត្រូវចាប់ផ្តើមទទួលការព្យាបាល ដោយ Antiretrovirals បន្ទាប់ពីបានបញ្ចប់ការព្យាបាលជំងឺរបេងបាន ២សប្តាហ៍ភ្លាម ដោយមិនគិតពីចំនួនកោសិកា CD4 ទេ

  ♦ក្រុម OI/ART ត្រូវផ្តល់ការព្យាបាលបង្ការដោយប្រើឱសថ Cotrimoxazol ជូនដល់ អ្នកជំងឺទាំងអស់ដែលផ្ទុកមេរោគអេដស៍ ហើយកើតជំងឺរបេង

– លោកវេជ្ជ. **សេខ ឧត្ដម** អនុប្រធានផ្នែកថែទាំជំងឺអេដស៍ NCHADS ធ្វើការបង្ហាញស្ដីពី ការផ្ដល់ការគាំទ្រ សំរាប់ការប្រើប្រាស់ឱសថ Isoniazid ( IPT ) ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ :

♦ ទទួលពត៌មាន និងចំណេះដឹងជាមូលដ្ឋានស្ដីពីការគាំទ្រ ការប្រើប្រាស់ឱសថ Isonizide សំរាប់ការព្យាបាលបង្ការជំងឺរបេងអោយបានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់

♦ យល់ច្បាស់អំពីតួនាទី និង ភារៈកិច្ចរបស់អ្នកអនុវត្តសកម្មភាពថែទាំ ព្យាបាល ( OI/ART teams, HBC teams, MMM/mmm ) ក្នុងការផ្ដល់ការគាំទ្រការ ប្រើប្រាស់ ឱសថ Isonizide សំរាប់ការព្យាបាលបង្ការជំងឺ របេងអោយបានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់

♦ ពិភាក្សាអំពីបញ្ហាប្រឈម និង ដំណោះស្រាយនានាដែលទាក់ទង នឹងការគាំទ្រ ការប្រើប្រាស់ឱសថ Isonizide សំរាប់ការព្យាបាលបង្ការជំងឺរបេងអោយបានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់

**ថ្ងៃទី ២ : ១៣ កក្កដា ២០១០**

**ពេលព្រឹក:**

– លោកវេជ្ជ. **គៀន សុរិយា** មន្ត្រីបច្ចេកទេស CENAT ធ្វើការបង្ហាញស្ដីពីការបង្ការការចំលងមេរោគរបេង នៅតាមបណ្ដាសេវាថែទាំ នានា ឬក្នុងអាគារ របេង រវាង អ្នកជំងឺរបេងទៅ មន្ត្រីសុខាភិបាល :

♦វិធានការណ៍បង្ការការចំលងមេរោគរបេង នៅតាមបណ្ដាសេវាថែទាំ និងព្យាបាលបន្តមានសារៈសំខាន់ ជាសារវន្ត ក្នុងការបង្ការការរាលដាលនៃមេរោគរបេងទៅកាន់អ្នកជំងឺ ដែលងាយឆ្លង ជំងឺនេះ បុគ្គលិកសុខាភិបាល សហគមន៍ និងអ្នកដែលរស់តាមកន្លែង ប្រមូលផ្ដុំនានា

♦នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ការរៀបចំការគ្រប់គ្រង និងសំរបសំរួលការអនុវត្តន៍ ការបង្ការការ ចំលងមេរោគរបេងនៅតាមសេវាថែទាំ និង ព្យាបាលបន្តត្រូវអនុវត្ត តាមគោលនយោបាយជាតិ សំរាប់បង្ការការចំលងរោគ

♦នៅតាមស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកនិមួយៗ និងរៀបចំអោយមានគណៈកម្មការ សំរាប់បង្ការ ការចំលងរោគ

-លោក. **ផាត់ ទាសនា** មន្ត្រីផ្នែកទិន្នន័យ NCHADS ធ្វើការបង្ហាញស្ដីពីការបង្ការការចំលងមេរោគ របេង នៅតាមបណ្ដាសេវាថែទាំ និងព្យាបាលបន្ត :

♦ឯកសារថ្មីសំរាប់ប្រើប្រាស់ជាមួយយុទ្ធសាស្ត្រ 3Is

♦ឯកសារដែលប្រើប្រាស់ជាមួយអ្នកជំងឺនៅពេលមកពិនិត្យ

♦ចំណុចកែសំរួល និងការបំពេញបញ្ជីអ្នកជំងឺឱកាសនិយមថ្មី និងការបំពេញបញ្ជីអ្នកជំងឺ ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ថ្មី

♦ឯកសារដែលប្រើប្រាស់ សំរាប់បំពេញរបាយការណ៍

♦អោយសិក្ខាកាមអនុវត្ត ការបំពេញទំរង់របាយការណ៍ត្រឹមត្រូវ

*ពេលល្ងាច :*

- ការលើកផែនការសំរាប់អនុវត្ត នូវសកម្មភាពនៃការអនុវត្ត យុទ្ធសាស្ត្រ Three I's នៅសេវា ថែទាំនិងការព្យាបាលបន្ត សំរាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដោយមន្ត្រីមជ្ឈមណ្ឌលទាំង ២ ។
- លោកវេជ្ជ. **ខៀវ ទាសនា** ប្រធានកម្មវិធីអេដស៍ខេត្ត ព្រៃវែង បង្ហាញពីផែនការសកម្មភាពការឆ្លើយតបរួមគ្នា សំរាប់ត្រីមាសទី ៣ និងទី ៤ ឆ្នាំ ២០១០ ។

កិច្ចប្រជុំនេះបានបញ្ចប់ដោយជោគជ័យនៅវេលាម៉ោង ១៦: ៣០ ល្ងាច បន្ទាប់ពីបានធ្វើការបូកសរុបលទ្ធផល នៃកិច្ចប្រជុំដោយលោកវេជ្ជ. សេង វុធី និង ពិធីប្រកាសបិទដោយលោកវេជ្ជ. **មាស ទុឡ្សី** អនុប្រធានមជ្ឈ មណ្ឌលជាតិ ប្រយុទ្ធនឹង ជំងឺអេដស៍ សើស្បែក និងកាមរោគ ។

ភ្នំពេញថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០

| បានឃើញ និងឯកភាព<br>ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ<br>នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | បានពិនិត្យដោយ<br>អនុប្រធានថែទាំជំងឺអេដស៍ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| វេជ្ជ. មាន_ឈីវុន | វេជ្ជ. សរិត សុវណ្ណរិទ្ធ | វេជ្ជ. ង៉ែត បុត្រា |